# សេចក្តីសង្ខេបប្រតិបត្តិរបស់ផែនការការចូលរួមរបស់ភាគីពាក់ព័ន្ធ

ផែនការការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) សម្រាប់គម្រោងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយអាស៊ីអាគ្នេយ៍នៃប្រទេសកម្ពុជា II (KH-SEADR II) ហើយអាចអនុវត្តបានចំពោះការវិនិយោគទាំងអស់ក្រោមគម្រោង KH-SEADRM II ដែលជាការផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក (WB)។ SEP ត្រូវបានរៀបចំឡើងស្របតាមក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ជាពិសេសស្តង់ដារបរិស្ថាន និងសង្គម 10 ស្តីពីការបង្ហាញព័ត៌មាន និងការចូលរួមពីភាគីពាក់ព័ន្ធ។ ឯកសារនេះគឺជាឯកសារដែលអាចកែប្រែបាន ហើយអាចត្រូវបានធ្វើបច្ចុប្បន្នភាពអំឡុងពេលអនុវត្តគម្រោង នៅពេលដែលស្ថានភាពក្នុងការអនុវត្តគម្រោងមានការផ្លាស់ប្តូរ។

## សង្ខេបការពិពណ៌នាគម្រោង

គោលបំណងនៃការអភិវឌ្ឍន៍គម្រោង (PDO) របស់គម្រោងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយអាស៊ីអាគ្នេយ៍នៃប្រទេសកម្ពុជា II (KH-SEADRM II) គឺដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា (RGC) នូវការកសាងឡើងវិញនូវភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទដែលងាយរងគ្រោះ ហើយរងផលប៉ះពាល់ដោយសារទឹកជំនន់ឆ្នាំ 2020 និងព្រឹត្តិការណ៍ទឹកជំនន់ដែលកើតឡើងម្តងទៀត។ ទន្ទឹមនឹងនេះដែរ គម្រោងនឹងជួយបញ្ជ្រាបការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅនៅក្នុងដំណើរការរបស់រដ្ឋាភិបាល។ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ក្នុងករណីមានវិបត្តិ ឬភាពអាសន្នដែលកើតឡើងនៅក្នុងខេត្តគោលដៅ គម្រោងនឹងផ្តល់ការឆ្លើយតបភ្លាមៗ ប្រកបដោយប្រសិទ្ធភាពចំពោះព្រឹត្តិការណ៍បែបនេះ។

ខេត្តគោលដៅទាំង 07 ក្រោមគម្រោង KH-SEADRM II រួមមាន ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប និងខេត្តត្បូងឃ្មុំ។ ដោយមានការគាំទ្រពីគម្រោង ការស្តាបនាឡើងវិញនូវផ្លូវ និងស្ពានដែលបានជ្រើសរើស នឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវភាពធន់ និងសុវត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីឆ្លើយតបទៅនឹងទឹកជំនន់ដែលកើតឡើងម្តងទៀត ក៏ដូចជាផលប៉ះពាល់ដែលអាចកើតមាននៃការប្រែប្រួលអាកាសធាតុ។ វិសាលភាពរបស់គម្រោងរួមមានការស្តារឡើងវិញនូវផ្លូវ និងស្ពានដែលរងការខូចខាតក្នុងអំឡុងពេលទឹកជំនន់ឆ្នាំ 2020។

គម្រោងដែលបានស្នើឡើងនឹងរួមបញ្ចូលចំនួនបួនផ្នែក៖ (1) ការពង្រឹងស្ថាប័នសម្រាប់ភាពធន់នឹងគ្រោះមហន្តរាយនៅថ្នាក់ជាតិ (2) ការកសាងឡើងវិញ និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទឱ្យមានភាពធន់ទ្រាំ (3) ការគ្រប់គ្រងគម្រោង និង(4) ការឆ្លើយតបពេលមានអាសន្ន។ គម្រោង KH-SEADRM II ក៏បង្កើតឡើងដោយផ្អែកទៅលើគម្រោង Cambodia Southeast Asia DRM Project (P160929, KH-SEADRM I) ដែលកំពុងដំណើរការផងដែរ។

## ផែនការការចូលរួមរបស់ភាគីពាក់ព័ន្ធ

ផែនការការចូលរួមរបស់ភាគីអ្នកពាក់ព័ន្ធនេះ មានគោលបំណងកំណត់រកអ្នកពាក់ព័ន្ធដែលមានសក្តានុពលក្នុងការរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ក្នុងសកម្មភាពគម្រោង ហើយមានបំណងឱ្យពួកគេចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ដ៏មានអត្ថន័យក្នុងអំឡុងពេលរៀបចំ និងការអនុវត្តគម្រោង។

ជាពិសេស SEP នឹងរក្សាទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធគម្រោងទាំងអស់ ដើម្បីទទួលបានមតិកែលម្អពីពួកគេឱ្យបានទាន់ពេលវេលាអំពីហានិភ័យបរិស្ថាន និងសង្គម និងផលប៉ះពាល់ជាបន្តបន្ទាប់ពេញមួយវដ្តនៃគម្រោង។ តាមរយៈការលើកកម្ពស់ការចូលរួមរបស់ភាគីអ្នកពាក់ព័ន្ធនៃគម្រោង ក្នុងដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ គម្រោងក៏មានគោលបំណងទទួលយកមតិកែលម្អរបស់អ្នកពាក់ព័ន្ធនៃគម្រោង ទៅក្នុងការរៀបចំ ការធ្វើផែនការ និងការអនុវត្តគម្រោង។ SEP ក៏កំណត់នូវឱកាសដែលអាចឱ្យក្រុមដែលរងផលប៉ះពាល់ ជាពិសេសក្រុមដែលមកពីក្រុមងាយរងគ្រោះ ដើម្បីចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំពិគ្រោះយោបល់របស់គម្រោង និងផ្តល់មតិកែលម្អជាពិសេសសម្រាប់សកម្មភាពដែលអាចប៉ះពាល់ដល់ពួកគេ។

ជាពិសេស SEP មានការរៀបចំឱ្យភាគីដែលពាក់ព័ន្ធនៃគម្រោង នូវការជូនដំណឹងអំពីព័ត៌មានរបស់គម្រោង ដូចជាហានិភ័យ និងផលប៉ះពាល់របស់គម្រោង វិធានការកាត់បន្ថយ និងពន្យល់ពីរបៀបដែលមតិរបស់អ្នកពាក់ព័ន្ធនឹងត្រូវបានប្រមូលតាមបណ្តាញទម្រង់បែបបទផ្សេងៗ និងរបៀបដែលមតិកែលម្អទាំងនោះត្រូវបានពិចារណា និងដាក់បញ្ចូលទៅក្នុងការរៀបចំ និងការអនុវត្តគម្រោង។ SEP ក៏បានពណ៌នាអំពីយន្តការដោះស្រាយបណ្តឹងសារទុក្ខរបស់គម្រោង និងរបៀបដែលភាគីពាក់ព័ន្ធប្រើប្រាស់ដើម្បីផ្តល់នូវមតិ យោបល់ ក៏ដូចជាការតវ៉ារបស់ពួកគេផងដែរ។ GRM បែបនេះមានប្រយោជន៍ជាពិសេសសម្រាប់អ្នកដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីគម្រោង ដូចជាអ្នកដែលរងផលប៉ះពាល់ដោយការប្រើប្រាស់ដីរបស់គម្រោង (ឧទាហរណ៍ដូចជា សម្រាប់ការពង្រីកផ្លូវ ឬប៉ះពាល់ដែលទាក់ទងនឹងលំហូរពលកម្មជាដើម)។

SEP ក៏រៀបរាប់អំពីវិធីសាស្រ្ត និងពេលវេលាជាក់លាក់ ដើម្បីកំណត់រកភាគីពាក់ព័ន្ធឱ្យចូលរួមក្នុងដំណាក់កាលផ្សេងគ្នាៗនៃវដ្តរបស់គម្រោង និងពិពណ៌នាអំពីប្រភេទព័ត៌មានដែលនឹងត្រូវបានបង្ហាញនៅពេលដែលសកម្មភាពពិគ្រោះយោបល់នឹងកើតឡើង ក៏ដូចជារបៀបដែលទស្សនៈរបស់អ្នកពាក់ព័ន្ធនឹងត្រូវបានយកមកពិចារណានៅក្នុងអំឡុងពេលការធ្វើផែនការ និងការអនុវត្តគម្រោង។

**និយមន័យនៃអ្នកពាក់ព័ន្ធនៃគម្រោង, ការកំណត់អ្នកពាក់ព័ន្ធ និងការវិភាគ**

SEP នេះ គ្របដណ្តប់អ្នកពាក់ព័ន្ធ 4 ប្រភេទ៖ (1) អ្នកពាក់ព័ន្ធដែលរងផលប៉ះពាល់ (2) អ្នកពាក់ព័ន្ធដែលចាប់អារម្មណ៍ និង(3) ក្រុមជនបាត់បង់ឱកាស/ងាយរងគ្រោះ (ផ្នែកទី 3)។ (1) សំដៅលើអ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោង។ (2) សំដៅលើអ្នកដែលចាប់អារម្មណ៍លើលទ្ធផលនៃគម្រោង ហើយ (3) សំដៅលើអ្នកដែលអាចរងផលប៉ះពាល់ជាអវិជ្ជមានពីលទ្ធផលគម្រោង ឬបានធ្វើឱ្យពួកគាត់មានសមត្ថភាពមានកម្រិតក្នុងការទទួលបានអត្ថប្រយោជន៍ពីគម្រោង។ SEP បានរៀបចំតារាងដែលសង្ខេបកម្រិតចំណាប់អារម្មណ៍ ផលប៉ះពាល់ និងឥទ្ធិពលដែលអ្នកពាក់ព័ន្ធប្រភេទនីមួយៗអាចមានលើគម្រោង។ យុទ្ធសាស្រ្តដើម្បីធានាថាមានការឆ្លុះបញ្ចាំងអត្ថប្រយោជន៍ របស់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ នៅក្នុងគម្រោងដូចមានចែងក្នុងតារាងទី 2 (ផ្នែកទី 3)។ គម្រោងនេះបានរៀបចំយុទ្ធសាស្រ្ត ដើម្បីធានាថារាល់ក្តីបារម្ភរបស់ក្រុមជនរងគ្រោះទាំងនេះ មានការដាក់បញ្ចូលក្នុងការអនុវត្តគម្រោង (ផ្នែកទី 4)។

**កម្មវិធីការចូលរួមរបស់អ្នកពាក់ព័ន្ធ**

SEP នេះកំណត់បាននូវប្រភេទនៃមធ្យោបាយប្រាស្រ័យទាក់ទងមួយចំនួន ដើម្បីចុះជួបអ្នកពាក់ព័ន្ធសម្រាប់ត្រៀមរៀបចំ និងអនុវត្តគម្រោង (តារាងទី 3) ។ មានមធ្យោបាយមួយចំនួនដែលគេអាចរកព័ត៌មាន អំពីគម្រោងបាន នឹងមានការរៀបចំកិច្ចពិគ្រោះយោបល់ស្តីពីទិដ្ឋភាពនានានៃគម្រោងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ តារាងទី 4

សង្ខេបព័ត៌មានអំពីវិធីសាស្ត្រទាំងនោះ។ ដើម្បីធានាថាយោបល់របស់ក្រុមងាយរងគ្រោះ ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំ និងការអនុវត្តគម្រោង ត្រូវពិចារណា និងរៀបចំឱ្យមានដំណើរការពិគ្រោះយោបល់ជាមួយពួកគាត់ដោយប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់យ៉ាងសមរម្យ។ ដំណើរការនេះរួមមាន ក). ការជូនដំណឹង ខ). ការរៀបចំកិច្ចពិគ្រោះយោបល់ និង គ). ការដាក់បញ្ចូលយោបល់ត្រឡប់ទៅក្នុងការរៀបចំ និងការអនុវត្តគម្រោង។ SEP នេះក៏ពិពណ៌នាអំពីដំណើរការប្រមូលយោបល់ផ្សេងៗពីអ្នកពាក់ព័ន្ធ តាមរយៈកិច្ចពិគ្រោះយោបល់ ដើម្បីយកមកពិចារណា និងរាយការណ៍ត្រឡប់ជូនអ្នកពាក់ព័ន្ធវិញផងដែរ។

## ធនធាន និងការទទួលខុសត្រូវអនុវត្ត SEP

អង្គភាពគ្រប់គ្រងគម្រោង (PMU) សម្រាប់គម្រោងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍នៃប្រទេសកម្ពុជា (KH-SEADRM II) ដែលមាននៅក្នុងក្រសួងអភិវឌ្ឍជនបទ គឺជាអ្នកទទួលខុសត្រូវអនវុត្ត SEP នេះ។ ចំណុចលម្អិតនៃលេខទំនាក់ទំនងសំខាន់ៗពីអង្គភាពគ្រប់គ្រងគម្រោង ដែលអ្នកអាចទូរស័ព្ទស្វែងរកព័ត៌មាន ផ្តល់យោបល់ ឬលើកជាសំណួរអំពីគម្រោង អាចរកបានក្នុងតារាងទី 7 (ផ្នែកទី 5) ។ អ្នកពាក់ព័ន្ធគម្រោងដូចជាជនរងផលប៉ះពាល់ពីគម្រោង និងជនចាប់អារម្មណ៍លើលទ្ធផលគម្រោង នឹងទទួលបានការលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពតាមដានគម្រោងនៅកម្រិតអនុគម្រោង។ តារាងទី 8 (ផ្នែកទី 7) កំណត់ការទទួលខុសត្រូវអនុវត្ត SEP ស្ថិតក្រោមគម្រោងនេះ។

## យន្តការដោះស្រាយវិវាទ (GRM)

នីតិវិធីលម្អិត ដើម្បីឱ្យជនរងផលប៉ះពាល់ដាក់នូវបណ្តឹងសារទុក្ខពាក់ព័ន្ធនឹងគម្រោង ក្តីបារម្ភ ឬក្តីមិនសុខចិត្តរួមទាំងទម្រង់ផ្សេងៗ គឺមានបញ្ជាក់នៅក្នុង SEP (ផ្នែកទី 6) ។ បណ្តឹងសារទុក្ខទាំងនេះ អាចពាក់ព័ន្ធនឹងបញ្ហាទិញដីពលកម្ម លក្ខខណ្ឌការងារ ការកេងប្រវ័ញ្ចផ្លូវភេទ ឬការប្រើប្រាស់គ្រឿងញៀន។ ការិយាល័យសង្គម និងបរិស្ថាន និងប្រធាន/នាយកគម្រោងនៅក្នុងក្រសួងអភិវឌ្ឍជនបទ គឺជាអ្នកទទួលខុសត្រូវចំពោះការបង្កើត និងរក្សាបញ្ជីដោះស្រាយវិវាទ។ ក្នុងករណីមានបណ្តឹងធ្ងន់ធ្ងរ គួរមានការជូនដំណឹងដល់ធនាគារពិភពលោក អំពីបណ្តឹងទាំងនោះមិនឱ្យហួសរយៈពេល ២៤ ម៉ោងក្រោយទទួលបានបណ្តឹង។ ឧបសម្ព័ន្ធទី 3 ពិពណ៌នាអំពីនីតិវិធីលម្អិត។

## ការតាមដាន និងវាយតម្លៃ SEP

ការតាមដាន និងវាយតម្លៃការអនុវត្ត SEP នឹងត្រូវធ្វើឡើងដោយគម្រោង ដើម្បីធានាថាមានការអនុវត្តសកម្មភាពនានាមានចែងក្នុង SEP បានយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា។ ស្ថិតក្រោមសេចក្តីណែនាំទូទៅរបស់ប្រធាន និងនាយកគម្រោង មន្ត្រីបរិស្ថាន និងសង្គម នៃក្រសួងអភិវឌ្ឍជនបទ ទទួលខុសត្រូវចំពោះសកម្មភាពតាមដានដែលបានពិពណ៌នានៅក្នុង SEP នេះ។ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង មន្ត្រីបរិស្ថាន និងសង្គមនឹងរៀបចំរបាយការណ៍តាមដានសកម្មភាព SEP ផ្ទៃក្នុងជារៀងរាល់ខែ ដោយរួមបញ្ចូលសកម្មភាពដែលបានអនុវត្តក្រោមផែនការជនជាតិដើមភាគតិច។ សកម្មភាពដែលអនុវត្តនៅក្នុងផែនការរុះរើការតាំងលំនៅដ្ឋាន និងមានការតាមដានពីសំណាក់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដូចមានចែងក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់របស់គម្រោង។ មន្ត្រីបរិស្ថាន និងសង្គមរបស់ក្រសួងអភិវឌ្ឍជនបទ នឹងធានាថាទទួលបានយោបល់ត្រឡប់ពីភាគីរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងបណ្តឹងសារទុក្ខដែលនឹងត្រូវយកមកពិចារណា និងដោះស្រាយឱ្យបានសមរម្យ និងរាយការណ៍ទាន់ពេលវេលាជូនភាគីរងផលប៉ះពាល់វិញ។ វិធីសាស្ត្រដូចបានបញ្ជាក់ដើម្បីរាយការណ៍ជូនអ្នកពាក់ព័ន្ធ អាចរកបាននៅក្នុងផ្នែកទី 7៕